# សារាចរណែនាំ

# ស្តីពីការប្រមូលថ្លៃវិភាគ

# របស់មន្ទីរពិសោធន៍

# ក្រសួងបរិស្ថាន

# ២០០២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខៈ ១៤០ ប.ស្ថ/ប.ក

រាជធានីភ្នំពេញ. ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២

# សារាចរណែនាំ

## ស្តីពី

## ការប្រមូលថ្លៃវិភាគរបស់មន្ទីរពិសោធន៍ក្រសួងបរិស្ថាន

ដោយពិនិត្យឃើញថា រយៈពេលកន្លងមកម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសមួយចំនួនបានមកបង់ថ្លៃវិភាគសំណាកសំណល់រឹង-រាវមានការយឺតយ៉ាវ ដែលជាហេតុនាំឱ្យក្រសួងបរិស្ថានប្រមូលចំណូលបង់ចូលថវិការដ្ឋពុំបានទាន់ពេលវេលា ។ ដូចនេះ ដើម្បីជំរុញការប្រមូលថ្លៃវិភាគសំណាកសំណល់រឹង-រាវផ្ទេរបញ្ចូលទៅក្នុងថវិការដ្ឋអោយទាន់ពេលវេលា ដោយផ្អែកលើព្រះរាជក្រមលេខនស/ រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យលេខ ២៧ អនក្រ / បក ចុះថ្ងៃទី ៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការត្រួតពិនិត្យការបំពុលទឹក អនុក្រឹត្យលេខ ៣៦ អនក្រ/បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងសំណល់រឹង និងប្រកាសអន្តរក្រសួងលេខ ៤៧៦ សហវ /បស្ថ / ប្រក ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់ថ្លៃវិភាគសំណល់សំរាប់មន្ទីរពិសោធន៍ក្រសួងបរិស្ថាន ក្រសួងបរិស្ថានសូមធ្វើការណែនាំដល់ម្ចាស់ប្រភពបំពុលរោងចក្រ សហគ្រាសទាំងអស់ ដូចខាងក្រោមៈ

១-ការបង់ថ្លៃវិភាគសំណាកសំណល់រឹង-រាវ ត្រូវធ្វើនៅការិយាល័យផែនការស្ថិតិ នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ទៅតាមតារាងថ្លៃវិភាគដែលភ្ជាប់មកជាមួយព្រឹត្តិប័ត្រវិភាគ ។

២-ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសត្រូវមកបង់ថ្លៃវិភាគយ៉ាងយូរ ១៥ថ្ងៃ ក្រោយទទួលបាននូវព្រឹត្តិប័ត្រវិភាគ និងតារាងថ្លៃវិភាគ ។

៣-ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសណា ដែលពុំបានមកបង់ប្រាក់ថ្លៃវិភាគតាមពេលកំណត់ខាងលើ ក្រសួងបរិស្ថាននឹងធ្វើការពិន័យជាទឹកប្រាក់ **ទ្វេរដង** ទៅនឹងទឹកប្រាក់សរុបដែលមាននៅក្នុងតារាងតំលៃវិភាគ។

៤-ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសណា ដែលពុំបានមកបង់ប្រាក់ថ្លៃវិភាគក្រោយរយៈពេល **៣០ថ្ងៃ** បន្ទាប់ពីបានទទួលនូវព្រឹត្តិប័ត្រនិងតារាងថ្លៃវិភាគ ក្រសួងបរិស្ថាននឹងធ្វើការពិន័យជាទឹកប្រាក់ **១.០០០.០០០៛ (មួយលានរៀល)** បន្ថែមទៅលើតំលៃវិភាគ។

ក្រោយទទួលបានសារាចរណែនាំនេះ ម្ចាស់ប្រភពបំពុល រោងចក្រ សហគ្រាសទាំងអស់ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។ ក្នុងករណីមិនអនុវត្ត រឺប្រព្រឹត្តល្មើសទៅនឹងចំណុចណាមួយនៃសេចក្ដីណែនាំខាងលើ ក្រសួងបរិស្ថាននឹងចាត់វិធានការតាមផ្លូវច្បាប់ ។

រដ្ឋមន្ត្រី

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា

**<u>ចំលងជូន</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

"ដើម្បីជូនជ្រាបជាពត៌មាន"

- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

"ដើម្បីមុខការ"

- ឯកសារ -កាលប្បវត្តិ